## រឿងទី១០៖ នាងរស់ កូនប្រសារដ៏ស្មោះត្រង់

**ខគម្ពីរ៖ នាងរស់ ១:១៦**

អ្នកម្ដាយទៅទីណា កូនក៏ទៅទីនោះដែរ អ្នកម្ដាយស្នាក់នៅកន្លែងណា កូនក៏ស្នាក់នៅកន្លែងនោះដែរ។
ជនជាតិរបស់អ្នកម្ដាយជាជនជាតិរបស់កូន ហើយព្រះរបស់អ្នកម្ដាយក៏ជាព្រះរបស់កូនដែរ។

កាលពីយូរលង់មកហើយ នៅក្នុងភូមិមួយឈ្មោះថាបេថ្លេហិមក្នុងស្រុកអ៊ីស្រាអែល បានកើតមានគ្រោះទុរ្ភិក្ស។
ដូច្នេះបុរសម្នាក់ឈ្មោះអេលីម៉ាឡេកជាអ្នកភូមិបេថ្លេហិមនោះ បាននាំភរិយានិងកូនប្រុសពីរនាក់ចេញទៅរស់នៅស្រុក ម៉ូអាប់។
ប៉ុន្តែ ប៉ុន្មានឆ្នាំក្រោយ បុរសនោះក៏ស្លាប់ដោយសារជំងឺបាត់ទៅ។
ក្រោយមក កូនប្រុសរបស់លោកក៏បានរៀបការជាមួយនិងស្ត្រីសាសន៍ម៉ូអាប់។ ពួកគេរស់នៅក្នុងស្រុកម៉ូអាប់អស់ រយៈពេល១០ឆ្នាំ។
បន្ទាប់មក កូនប្រុសទាំងពីរនោះ ក៏បានស្លាប់ដោយជំងឺ ទុកណាអូមីជាម្ដាយ ឱ្យនៅជាមួយនិងកូនប្រសារស្រីច្បង ឈ្មោះនាងរស់ និងអ៊ើរប៉ា ។
ក្រោយមក ស្រុកអ៊ីស្រាអែលដែលជាស្រុកកំណើតរបស់ណាអូមីក៏មានភាពសប្បូរសប្បាយវិញ។
ណាអូមីនឹករលឹកចង់ត្រឡប់ទៅស្រុកកំណើតវិញជាខ្លាំង។



មុនពេលត្រឡប់ទៅស្រុកកំណើតវិញ ណាអូមីបានហៅអ៊ើរបា និងនាងរស់ជាកូនប្រសារទាំងពីរមកជួប។
«ពេលនេះ ប្ដីរបស់កូនក៏លែងនៅដែរ ចូរកូនត្រឡប់ទៅនៅជាមួយឪពុកម្ដាយកូនរៀងៗខ្លួនវិញចុះ ចំណែកម៉ែ នឹងត្រឡប់ទៅស្រុកកំណើតម៉ែវិញហើយ»។
អ្នកទាំងបី ទ្រហោយំជាមួយគ្នា។ ចុងក្រោយអ៊ើរប៉ាក៏សម្រេចចិត្តត្រឡប់ទៅផ្ទះខ្លួនវិញទាំងទឹកភ្នែក។
ប៉ុន្តែ នាងរស់ជាកូនប្រសារដ៏ល្អវិញ នាងមិនបានចាកចេញពីម្ដាយក្មេកនាងឡើយ។ នាងរស់បាននិយាយទៅកាន់ ណាអូមីថា៖
«អ្នកម្ដាយទៅទីណា កូនក៏ទៅទីនោះដែរ ហើយព្រះរបស់អ្នកម្ដាយ ក៏ជាព្រះរបស់កូនដែរ។ ដូច្នេះ កុំដេញកូនឱ្យទៅ ណាទៀតអី»។
ដូច្នេះ ណាអូមី និងនាងរស់ក៏បានចាកចេញទៅភូមិបេថ្លេហិមជាស្រុកកំណើតជាមួយគ្នា។
អ្នកភូមិបេថ្លេហិមទាំងអស់ មានការភ្ញាក់ផ្អើលជាខ្លាំងពេលឃើញណាអូមី និងនាងរស់។
រដូវកាលប្រមូលផលពីស្រែក៏បានមកដល់។ មនុស្សម្នាបានចេញទៅច្រូតស្រូវតាមស្រែ។
ប៉ុន្តែ ណាអូមីវិញ នាងមិនមានស្រែ ហើយក៏មិនមានអ្នកជួយនាងដែរ។
នាងរស់ជាកូនប្រសារល្អ នាងបានចេញទៅរើសស្រូវមកទុកញ៉ាំ។
មានពេលមួយ ពេលដែលនាងរស់កំពុងតែរើសស្រូវក្នុងស្រែ អូបូសដែលជាម្ចាស់ស្រែបានឃើញនាង។



បូអូសបានសួរទៅអ្នកបម្រើថាៈ «តើនាងនោះជានរណា»?
អ្នកបម្រើបានឆ្លើយឡើងថាៈ «នាងជានាងរស់កូនប្រសារដ៏ល្អរបស់ណាអូមីដែលមកតាមណាអូមីតាំងពីម៉ូអាប់មក»។
បូអាសបាននិយាយទៅបាវបម្រើថាៈ «ចូរទម្លាក់គួរស្រូវឱ្យច្រើន ដើម្បីឱ្យនាងបានរើសឱ្យបានច្រើន»។
ពេលនាងរស់ទៅដល់ផ្ទះ ម្ដាយក្មេកក៏សួរនាងថាៈ «តើកូនរើសស្រូវមកពីណា ម៉េចក៏បានច្រើនយ៉ាងនេះ?»
«ម៉ែ គឺខ្ញុំបានទៅរើសនៅក្នុងស្រែរបស់លោកម្ចាស់ម្នាក់ឈ្មោះបូអូស»។
ណាអូមីបាននិយាយថាៈ «លោកម្នាក់នោះគឺជាសាច់ញាតិយើង តទៅមុខ កូនទៅរើសតែក្នុងស្រែរបស់លោកបានហើយ»។
ណាអូមីមានគំនិតចង់ឱ្យនាងរស់បានរៀបការជាមួយបូអូស។
ហើយបូអូសក៏ពេញចិត្តនាងរស់ដ៏ស្រស់ស្អាតនិងឧស្សាហ៍ព្យាយាមមករើសស្រូវរាល់ថ្ងៃដែរ។
ដូច្នេះ ណាអូមីក៏អនុញ្ញាតឱ្យនាងរស់ជាកូនប្រសារដ៏ល្អរៀបការជាមួយបូអូស។
ទីបំផុតបូអូស និងនាងរស់ក៏បានរៀបការនឹងគ្នា។ ព្រះជាម្ចាស់បានប្រទានពរដល់នាងរស់ និងបូអូស នូវកូនប្រុសម្នាក់។
ហើយណាអូមីក៏មានអំណរអរសប្បាយដែរ។
បូអូសបានដាក់ឈ្មោះឱ្យកូនប្រុសម្នាក់នោះថា «អូបិឌ»។
អូបិឌម្នាក់នេះ គឺជាជីតារបស់ស្ដេចដាវីឌ ដែលជាស្ដេចដ៏អស្ចារ្យនៃស្រុកអ៊ីស្រាអែល។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើនាងរស់ជាជនជាតិអ្វី?

---

b. តើកូនរបស់នាងរស់ និងបូអូស ជាជីតារបស់អ្នកណា?



---

c. តើនាងរស់បាននិយាយសារភាពដូចម្ដេចខ្លះ នៅពេលដែលនាងសុំតាមម្ដាយក្មេកទៅភូមិបេថ្លេហិម?

---

---

● សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (នាងរស់ ១៖១៦)

> អ្នកម្ដាយទៅទីណា កូនក៏ទៅទីនោះដែរ អ្នកម្ដាយស្នាក់នៅកន្លែងណា កូនក៏ស្នាក់នៅកន្លែងនោះដែរ។ ជនជាតិរបស់អ្នកម្ដាយជាជនជាតិរបស់កូន ហើយព្រះរបស់អ្នកម្ដាយក៏ជាព្រះរបស់កូនដែរ។



**សកម្មភាពទី២** កាត់តួអង្គចេញ ហើយបង្កើតតុក្កតាម្រាមដៃ។



www.kidsworship.kr

Ministry of Christian Publishing

ឈ្មោះ: